

# ងូតទឹកភ្លៀង

All Children Reading - Cambodia

Ouk Ratha

letsreadasia.org



សូឡី និងស្រីឡាំជាបងប្អូននឹងគ្នា។
ពួកគេងូតទឹកភ្លៀងនៅមុខផ្ទះ។



ពួកគេត្រងទឹកដាក់ពាង។



ពួកគេឃើញផ្លេកបន្ទោរភ្លឹបភ្លែតៗ និង
ឮផ្គរលាន់ សូរខ្លាំងៗ។



ស្រីឡាំប្រាប់សូឡី ៖ កុំប៉ះដែកនៅពេល
កំពុងភ្លៀង។



ស្រីឡាំយោលទោងនៅក្រោមដើម
ស្វាយ។



សូឡីប្រាប់ស្រីឡាំវិញ ៖ កុំនៅក្រោម
ដើមឈើនៅពេលកំពុងភ្លៀង។



មើលចុះ! ក្រោយភ្លៀងរាំង ផ្ការីកស្រស់
ស្អាត។



ពេលនេះ ខ្ញុំហេវណាស់។



ងូតទឹកភ្លៀង ការណែនាំបន្ថែមអំពី
ការប្រើប្រាស់សៀវភៅ សៀវភៅរឿង
នេះ បានផលិតឡើងដោយមានភ្ជាប់
នូវសកម្មភាពនៅក្នុងទំព័រនីមួយ
ៗ សម្រាប់ឱ្យសិស្សធ្វើសកម្មភាព
តាមសាច់រឿង។ នៅក្នុងសកម្មភាព
ទាំងនោះមានប្រើនូវញាណទាំ៥ និង
ចលនាផងដែរ។ លោកគ្រូអ្នកគ្រូ
អាចអានរឿង បន្ទាប់មកសិស្សប្តូរ
វេនគ្នាដើម្បីធ្វើសកម្មភាព។ អត្ថបទ
រឿង - សូឡី និងស្រីឡាំជាបងប្អូន
នឹងគ្នា។ ពួកគេងូតទឹកភ្លៀងនៅមុខ
ផ្ទះ។ សកម្មភាព - គ្រូបាញ់ទឹកដាក់
នៅលើបាតដៃសិស្ស សម្ភារៈដែល



ត្រូវប្រើ - គ្មដបទឹកតូច អត្ថបទរឿង - ពួកគេត្រងទឹក ដាក់ពាង។ សកម្មភាព - គ្រូឱ្យសិស្សឃ្លរទឹកដែលនៅក្នុងកូនធុង សម្ភារៈដែលត្រូវប្រើ - កូនធុងទឹក អត្ថបទរឿង - ពួកគេឃើញផ្លេកបន្ទោរភ្លឺបភ្លែតៗ និងឮផ្គរលាន់សូរក្ខាំងៗ។ សកម្មភាព - គ្រូបង្ហាញរូបផ្លេកបន្ទោរ និងសំឡេងផ្គរលាន់ដែលមាននៅក្នុងទូរស័ព្ទ ឬគ្រូអាចនាំសិស្សធ្វើសំឡេងផ្គរលាន់ ដោយគោះតុ ឬគោះវត្ថុផ្សេងៗដែលស្រដៀងគ្នា សម្ភារៈដែលត្រូវប្រើ អត្ថបទរឿង - ស្រីឡាំប្រាប់សូឡី ៖ កុំប៉ះដែកនៅពេលកំពុងភ្លៀង។ សកម្មភាព - គ្រូបង្ហាញ



ដែកដល់សិស្ស សម្ភារៈដែលត្រូវប្រើ
- ដែកតូចវែង អត្ថបទរឿង - ស្រីឡាំ
យោលទោងនៅក្រោមដើមស្វាយ។
សកម្មភាព - គ្រូឱ្យសិស្សអង្គុយ ហើយ
យោលជើង សម្ភារៈដែលត្រូវប្រើ - គ្មាន
អត្ថបទរឿង - សូឡីប្រាប់ស្រីឡាំវិញ
៖ កុំនៅក្រោមដើមឈើនៅពេលកំពុង
ភ្លៀង។ សកម្មភាព - គ្រូឱ្យសិស្សម្នាក់
ចាប់ទាញដៃសិស្សម្នាក់ទៀតចេញពី
កន្លែងមួយ សម្ភារៈដែលត្រូវប្រើ - គ្មាន
អត្ថបទរឿង - មើលចុះ! ក្រោយភ្លៀង
រាំង ផ្ការីកស្រស់ស្អាត។ សកម្មភាព -
គ្រូឱ្យសិស្សហិតផ្កាមួយចំនួន ដូចជាផ្កា
កុលាប ផ្កាម្លិះ... សម្ភារៈដែលត្រូវប្រើ



- ផ្កាអ្វីក៏បាន អត្ថបទរឿង - ពេលនេះ ខ្ញុំហេវណាស់។ សកម្មភាព - គ្រូឱ្យសិស្សហិតក្លិន និងភ្លក់មីស្រុសទឹកក្តៅ សម្ភារៈដែលត្រូវប្រើ - មីស្រុសទឹកក្តៅមួយចាន គោលបំណងក្នុងការប្រើវិធីសាស្ត្រនេះ គឺដើម្បីឱ្យកុមារអាចចូលរួមស្តាប់ការនិទានរឿងទៅតាមកម្រិតសកម្មភាពផ្សេងៗគ្នារបស់ពួកគេ។ សិស្សខ្លះអាចចូលរួមពិភាក្សាអំពីគំនិតនៅក្នុងសាច់រឿង។ សិស្សខ្លះទៀតអានរៀន នូវពាក្យថ្មីៗ និងរៀនពីការប្តូរវេនគ្នាម្តងម្នាក់ៗ។ ចំណែកឯសិស្សដទៃទៀត ជាពិសេស កុមារខ្សោយសតិបញ្ញាធ្ងន់ធ្ងរ គឺដើម្បីឱ្យ



ពួកគេចេះបង្ហាញទឹកមុខ ឬកាយវិការ អំពីវត្ថុដែលពួកគេចូលចិត្ត ឬមិនចូលចិត្ត។ សៀវភៅនេះអាចធ្វើឱ្យសិស្សផ្សេងៗទៀត មានភាពសប្បាយរីករាយ និងមានអន្តរសកម្មភាពជាមួយគ្នា ក្នុងការស្តាប់រឿងនិទាន និងធ្វើឱ្យសិស្សទាំងនោះមានការចាប់អារម្មណ៍ជាមួយសៀវភៅ។



រឿងនិទាននេះបង្ហាញពីបងប្អូនពីរនាក់ គឺស្រីឡាំ និងសូឡី ដែលចូលចិត្តងូតទឹកភ្លៀងដូចកុមារដទៃទៀតដែរ។ ពួកគេសប្បាយរីករាយក្នុងការលេងទឹកភ្លៀងនៅខាងមុខផ្ទះ ប្រកបដោយភាពប្រុងប្រយ័ត្ន។ ស្រីឡាំ និងសូឡីបានឃើញ ឮ ធុំក្លិន និងប៉ះពាល់វត្ថុផ្សេងៗជាច្រើន តាមរយៈការធ្វើសកម្មភាពរបស់ពួកគេ នៅអំឡុងពេលងូតទឹកភ្លៀង។ យើងអាចប្រើសៀវភៅនេះសម្រាប់ មត្តេយ្យសិក្សា និងបឋមសិក្សា ឬអាចប្រើនៅផ្ទះក៏បាន។ យើងបង្កើតសៀវភៅនេះឡើងដើម្បីឱ្យកុមារទាំងអស់អាចប្រើប្រាស់



បាន រួមទាំងកុមារខ្សោយសតិបញ្ញា ផងដែរ។ គោលបំណងក្នុងការបង្កើត សៀវភៅនេះឡើងគឺដើម្បីលើកកម្ពស់ នូវការចូលរួម និងការសិក្សារបស់កុមារ តាមរយៈការធ្វើសកម្មភាពសប្បាយៗ នៅអំឡុងពេលនៃការស្តាប់ និងអាន រឿងនិទាន។

អត្ថបទរឿងដោយ/ Text by All Children Reading-Cambodia (a USAID funded project supporting the Ministry of Education, Youth and Sport) and partners រូបគំនូរដោយ អ៊ុក រដ្ឋា Illustration by Ouk Ratha រចនាទំព័រដោយ អង្គការស៊ីប៉ា Design by Sipar This work is released under Creative Commons CC BY 4.0

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
ងូតទឹកភ្លៀង, author: All Children Reading - Cambodia . illustrator: by Ouk Ratha. Published by All Children Reading - Cambodia, © All Children Reading - Cambodia. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/